## អនុក្រឹត្យលេខ ១១៦ អនក្រ.បក
## ស្តីពីការគ្រប់គ្រងការផលិត និងការធ្វើអាជីវកម្មផែនទី
## នៃព្រះរាជាណាចក្រកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញ អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ១៩៩៩

## សំរេច

**មាត្រា ១.-** អនុក្រឹត្យមានគោលដៅទប់ស្កាត់ការផ្សព្វផ្សាយ ការប្រើប្រាស់ជាសាធារណៈនូវផែនទី ដែលមិនឆ្លើយតបទៅនឹងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយតំរូវឲ្យមានការគ្រប់គ្រងលើការផលិត និងការធ្វើអាជីវកម្មផែនទី គ្រប់ប្រភេទនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-** អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាស្ថាប័នតែមួយគត់ ដែលមានភារកិច្ចកសាងផែនទីភូមិសាស្ត្រគោល ឬផែនទីមានលេខានៃព្រះរាជាណាចក្រកម្ពុជា និងគ្រប់គ្រងត្រួតពិនិត្យរាល់ការបោះពុម្ពផ្សាយផែនទីគ្រប់ប្រភេទរបស់ព្រះរាជាណាចក្រកម្ពុជា សំដៅឲ្យឯកភាពទូទាំងប្រទេស ។

**មាត្រា ៣.-** រាល់ការកសាងផែនទីជំនាញគ្រប់ប្រភេទតាមជំនាញរបស់អង្គភាពនីមួយៗ ត្រូវសហការ និងប្រើប្រាស់ទិន្នន័យផែនទីគោលរបស់នាយកដ្ឋានភូមិសាស្ត្រ នៃនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ហើយត្រូវផ្តល់ជូនមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នូវផែនទីដែលបានកសាងហើយ ចំនួនពីរច្បាប់ ដើម្បីតំកល់ទុកជាឯកសារ ។

រាល់ការបោះពុម្ពផែនទីកម្ពុជាគ្រប់ប្រភេទ ទាំងនៅក្នុង និងក្រៅប្រទេស សំរាប់ធ្វើអាជីវកម្ម ត្រូវមានការអនុញ្ញាត និងចុះទិដ្ឋាការពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុន ។

ការនាំចូល ការប្រើប្រាស់ជាសាធារណៈ អាចធ្វើបានចំពោះតែផែនទី ដែលមានទិដ្ឋាការពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ៤.- ជនណាដែលបានធ្វើការចំលង ឬថតចំលង ឬកែច្នៃខុសពីច្បាប់ដើមនូវរាល់ទិន្នន័យផែនទីគោល ធ្វើការបោះពុម្ពផ្សព្វផ្សាយផែនទី ដោយមិនស្របតាមមាត្រា ៣ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៥.- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួង និង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ១១៧ អនក្រ.បក

## ស្តីពីការបែងចែកចំណូលថវិកាឆ្លងទៅរបស់រដ្ឋ

## តាមឯកពុកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០០

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.